# ព្រះរាជក្រម

នស/រកម/១០០៩/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យយោបល់តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច ទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីពាណិជ្ជកម្មសេវាកម្មនៃកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខានៅទីក្រុងសេបូ ប្រទេសហ្វីលីពីន នាថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៩

នស/រកម.០៩១០.១០៣០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋមន្ត្រីស្តីទី

ហត្ថលេខា

**ភឹម ស៊ីថន**

លេខ ៤៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

# កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌ ស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋប្រជាមានិតចិន

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារូស្សាឡាម (ប្រ៊ុយណេដារូស្សាឡាម) ព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) សាធារណរដ្ឋឥណ្ឌូនេស៊ី (ឥណ្ឌូនេស៊ី) សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ (ឡាវ PDR) ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា (មីយ៉ាន់ម៉ា) សាធារណរដ្ឋហ្វីលីពីន (ហ្វីលីពីន) សាធារណរដ្ឋសិង្ហបុរី (សិង្ហបុរី) រាជាណាចក្រថៃឡង់ដ៍ (ថៃឡង់ដ៍) សាធារណរដ្ឋសង្គមនិយមវៀតណាម (វៀតណាម) ប្រទេសជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា "អាស៊ាន" ឬ "ប្រទេសជាសមាជិកអាស៊ាន" ឬប្រទេសនីមួយៗ "ប្រទេសសមាជិកអាស៊ានមួយ") និងសាធារណរដ្ឋប្រជាមានិតចិន ("ចិន") ។

**ដោយរំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ (កិច្ចព្រមព្រៀងក្របខ័ណ្ឌ) រវាងអាស៊ាន និងចិន (ហៅកាត់ថា "បណ្តាភាគី" ឬ ភាគីនីមួយៗ ដែលសំដៅលើប្រទេសជាសមាជិកអាស៊ានមួយ ឬប្រទេសចិន គឺជា "ភាគីមួយ") ដែលបានចុះហត្ថលេខាដោយប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកអាស៊ាន និងប្រទេសចិន នៅភ្នំពេញថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០០២ ។

**ដោយរំលឹកឡើងវិញ** នូវមាត្រាទី៤ និង ទី៨ (៣) នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីការបញ្ចប់ឱ្យបានឆាប់នូវការចរចាកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម ដើម្បីធ្វើសេរីភាវូបនីយកម្មជាបណ្តើរៗ និងលុបបំបាត់ឱ្យបានច្រើននូវការរើសអើសទាំងអស់ និង/ឬ ហាមឃាត់ចំពោះវិធានការរើសអើងថ្មីៗ ឬច្រើនថែមទៀត ចំពោះពាណិជ្ជកម្មសេវាកម្មរវាងបណ្តាភាគីពាក់ព័ន្ធ និងធ្វើការពង្រីកនូវជំរៅ និងទំហំនៃពាណិជ្ជកម្មសេវាកម្ម ដោយមានវិសាលភាពគ្របដណ្តប់ទៅលើវិស័យជាច្រើនទៀត លើសពីការសន្យារបស់ប្រទេសជាសមាជិកអាស៊ាន និងចិនជាមួយនឹងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

**ដោយប្រាថ្នា** ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យសេវាកម្មរវាងភាគីទាំងអស់ ដើម្បីបង្កើននូវប្រសិទ្ធភាព និងភាពប្រកួតប្រជែង ព្រមទាំងធ្វើឱ្យការផ្គត់ផ្គង់ និងការចែកចាយសេវាបានសំបូរបែបសំរាប់អ្នកផ្គង់ផ្គង់សេវារៀងៗខ្លួន នៃបណ្តាភាគី ដើម្បីធ្វើការអនុវត្តឱ្យស្របទៅនឹងពេលកំណត់ ដែលបានព្រមព្រៀងគ្នាទៅវិញទៅមក ពីគ្រប់ភាគីទាំងអស់នៃកិច្ចព្រមព្រៀងក្របខណ្ឌ ដោយយកចិត្តទុកដាក់ដល់វិស័យ

ដែលរសើបរបស់ភាគីទាំងអស់ និងគិតគូដល់ប្រព្រឹត្តកម្មដោយឡែក និងមានភាពទន់ភ្លន់ចំពោះប្រទេសជាសមាជិកអាស៊ានថ្មី រួមមាន កម្ពុជា ឡាវ PDR មីយ៉ាន់ម៉ា និងវៀតណាម ។

**ដោយទទួលស្គាល់** នូវសិទ្ធិរបស់ភាគីទាំងអស់ នៅក្នុងការត្រួតពិនិត្យ និងចេញបទប្បញ្ញត្តិថ្មីៗ ស្តីពីការផ្គត់ផ្គង់សេវាកម្ម នៅក្នុងបូរណភាពទឹកដីនៃបណ្តាភាគី ដើម្បីបំពេញទិសដៅរបស់គោលនយោបាយជាតិ ហើយដោយសារភាពខុសគ្នានៃកំរិតការអភិវឌ្ឍន៍បទប្បញ្ញត្តិសេវាកម្មនានា នៅក្នុងទឹកដីនៃបណ្តាភាគី និងតម្រូវការជាក់ស្តែងរបស់បណ្តាភាគីទាំងនោះ ក្នុងការអនុវត្តសិទ្ធិនេះ ។

**បានព្រមព្រៀងដូចតទៅ :**

## ជំពូក I : និយមន័យ និងវិសាលភាព

### មាត្រា ១

### និយមន័យ

**សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :**

(ក) "សេវាសំរាប់ផ្គត់ផ្គង់អាជ្ញាធររដ្ឋាភិបាល" មានន័យថា ជាសេវាដែលមិនត្រូវបានផ្គត់ផ្គង់ដើម្បីផលចំណេញខាងពាណិជ្ជកម្ម និងមិនមែនសេវាដែលប្រកួតប្រជែងជាមួយអ្នកផ្គត់ផ្គង់សេវាមួយ ឬច្រើនទៀត ។

(ខ) "វត្តមានពាណិជ្ជកម្ម" មានន័យថា ជាប្រភេទធុរកិច្ច ឬការបង្កើតវិជ្ជាជីវៈណាមួយ រួមបញ្ចូលទាំង :

(i) ការបង្កើត ការទទួលបាន ឬ ការរក្សានីតិបុគ្គលដែលមានស្រាប់ ឬ

(ii) ការបង្កើត ឬការរក្សាប្រើប្រាស់សាខាក្រុមហ៊ុន ឬការិយាល័យតំណាង

នៅក្នុងដែនដីនៃភាគីមួយ សំរាប់គោលបំណងនៃការផ្គត់ផ្គង់សេវាមួយ ។

(គ) "ពន្ធផ្ទាល់"រួមបញ្ចូលនូវប្រភេទពន្ធទាំងអស់លើចំណូលសរុប លើមូលធនសរុប ឬលើសមាសធាតុចំណូល ឬមូលធន រួមមាន ពន្ធលើចំណូលពីការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិ ពន្ធលើអចលនទ្រព្យ មរតក និងអំណោយ និងពន្ធលើបរិមាណសរុបនៃប្រាក់ឈ្នួល ឬប្រាក់បៀវត្សរ៍ ដែលបើកដោយសហគ្រាសនានា ព្រមទាំងពន្ធលើកំណើនមូលធន ។

(ឃ) "GATS" មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ។

(ង) "នីតិបុគ្គល" មានន័យថា នីតិបុគ្គលណាមួយ ដែលត្រូវបានបង្កើត ឬរៀបចំឡើងក្រោមច្បាប់ជាធរមាន ទោះបីជាដើម្បីរកប្រាក់ចំណេញ ឬក្នុងគោលបំណងដទៃទៀតក្តី និងទោះបីជា កម្មសិទ្ធិរបស់ឯកជន ឬ

កម្មសិទ្ធិរបស់រដ្ឋាភិបាលក្តី ដែលរួមមាន សាជីវកម្ម ក្រុមហ៊ុនទទួលភារៈគ្រប់គ្រង ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនចំរុះទុន សហគ្រាសឯកកម្មសិទ្ធិ ឬ សមាគម។

(ច) "នីតិបុគ្គលរបស់ភាគីមួយទៀត" មានន័យថា នីតិបុគ្គលដែលៈ

(i) ត្រូវបានបង្កើត ឬរៀបចំឡើងនៅក្រោមច្បាប់របស់ភាគីផ្សេងទៀត និងចូលរួមក្នុងប្រតិបត្តិការធុរកិច្ចជាដុំកំភួន នៅក្នុងដែនដីរបស់ភាគីនោះ ឬភាគីដទៃទៀត ឬ

(ii) ក្នុងករណីនៃការផ្គត់ផ្គង់សេវាតាមរយៈវត្តមានពាណិជ្ជកម្ម ការកាន់កាប់កម្មសិទ្ធិ ឬ ការគ្រប់គ្រងដោយៈ

១. រូបវន្តបុគ្គលនៃភាគីនោះ ឬ

២. នីតិបុគ្គលនៃភាគីដទៃទៀត ដែលបានបង្ហាញនៅក្នុងកថាខណ្ឌរង (i)

(ឆ) នីតិបុគ្គល គឺ :

(i) ត្រូវបានកាន់កាប់កម្មសិទ្ធិ ដោយបុគ្គលទាំងឡាយនៃភាគីមួយ ប្រសិនបើលើសពី៥០ ភាគរយនៃភាគទុនរបស់ក្រុមហ៊ុន គឺត្រូវបានកាន់កាប់សិទ្ធិដោយបុគ្គលទាំងឡាយនៃភាគីនោះ

(ii) ត្រូវបានគ្រប់គ្រង ដោយបុគ្គលទាំងឡាយនៃភាគីមួយ ប្រសិនបើបុគ្គលនោះមានអំណាចតែងតាំងសមាសភាពនាយកភាគច្រើនរបស់ខ្លួន ឬមានសិទ្ធិតាមផ្លូវច្បាប់ ក្នុងការបញ្ជាឱ្យអនុវត្តសកម្មភាពរបស់ខ្លួន

(iii) ត្រូវបានចងសម្ព័ន្ធ ជាមួយបុគ្គលម្នាក់ផ្សេងទៀត នៅពេលដែលបុគ្គលនោះគ្រប់គ្រង ឬ ត្រូវបានគ្រប់គ្រងដោយបុគ្គលម្នាក់ផ្សេងទៀត ឬនៅពេលដែលបុគ្គលនោះ និងបុគ្គលម្នាក់ផ្សេងទៀតត្រូវបានគ្រប់គ្រងដូចគ្នាដោយបុគ្គលតែមួយ

(ជ) "វិធានការ" មានន័យថា វិធានការណាមួយដែលធ្វើឡើងដោយភាគីមួយ ទោះជាក្នុងទំរង់ជាច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសំរេច វិធានការរដ្ឋបាល ឬទំរង់ផ្សេងទៀត

(ឈ) "វិធានការដោយភាគីទាំងអស់" មានន័យថា ជាវិធានការនានាដែលធ្វើឡើងដោយៈ

(i) រដ្ឋាភិបាល និងអាជ្ញាធរថ្នាក់កណ្តាល តំបន់ ឬ មូលដ្ឋាន និង

(ii) អង្គការក្រៅរដ្ឋាភិបាលនានា ដែលប្រើប្រាស់អំណាចប្រតិភូកម្មដោយរដ្ឋាភិបាល ឬអាជ្ញាធរថ្នាក់កណ្តាល តំបន់ ឬមូលដ្ឋាន។

(ញ) "វិធានការនានារបស់ភាគីទាំងអស់ ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម" រួមមានវិធានការទៅលើ :

(i) ការទិញ ការទូទាត់ ឬប្រើប្រាស់សេវា

(ii) សិទ្ធិចូលរួម និងប្រើប្រាស់ ទាក់ទិននឹងការផ្គត់ផ្គង់សេវា សេវាដែលតម្រូវដោយបណ្តាភាគីសំរាប់ផ្គត់ផ្គង់ដល់សាធារណជនជាទូទៅ

(iii) វត្តមាន រួមបញ្ចូល វត្តមានពាណិជ្ជកម្ម វត្តមានបុគ្គលមកពីភាគីម្ខាង ដើម្បីផ្គត់ផ្គង់សេវានៅក្នុងដែនដីនៃភាគីម្ខាងទៀត

(ដ) "អ្នកផ្គត់ផ្គង់ផ្តាច់មុខមួយចំពោះសេវាកម្មមួយ" មានន័យថា គឺជាបុគ្គលសាធារណៈ ឬឯកជន នៅក្នុងទីផ្សារពាក់ព័ន្ធនៃដែនដីរបស់ភាគីមួយ ដែលត្រូវបានអនុញ្ញាត ឬបានបង្កើតឡើងជាផ្លូវការ ឬជាឥទ្ធិពលដោយភាគីនោះ ក្នុងរូបភាពជាអ្នកផ្គត់ផ្គង់ផ្តាច់មុខនូវសេវាប្រភេទនោះ

(ឋ) "រូបវន្តបុគ្គលនៃភាគីមួយផ្សេងទៀត" មានន័យថា រូបវន្តបុគ្គលដែលស្នាក់អាស្រ័យនៅក្នុងដែនដីរបស់ភាគីផ្សេងទៀត ឬស្នាក់អាស្រ័យនៅកន្លែងផ្សេង និងអ្នកដែលស្ថិតនៅក្រោមច្បាប់នៃភាគីផ្សេងទៀតនោះ:

(i) ជាជនជាតិនៃភាគីដទៃទៀតនោះ ឬ

(ii) មានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍[9] ក្នុងដែនដីភាគីដទៃទៀតនោះ ក្នុងករណីដែលភាគីមួយផ្តល់ប្រព្រឹត្តិកម្មចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ ស្ទើរតែដូចគ្នាទាំងស្រុងនឹងប្រព្រឹត្តិកម្មដែលផ្តល់ចំពោះជនជាតិខ្លួន ពាក់ព័ន្ធនឹងវិធានការដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវា-កម្ម ដូចបានជូនដំណឹងនៅក្នុងការទទួលយក ឬការចូលជាភាគីនៃកិច្ចព្រមព្រៀងនេះ ឱ្យតែពុំមានភាគីណាមួយត្រូវបានដាក់កាតព្វកិច្ច ឱ្យផ្តល់ចំពោះអ្នកមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍នូវប្រព្រឹត្តិកម្ម ដែលមានភាពអនុគ្រោះច្រើនជាងប្រព្រឹត្តិកម្មដែលត្រូវផ្តល់ដោយភាគីដទៃទៀតនោះ ចំពោះអ្នកស្នាក់នៅអចិន្ត្រៃយ៍ទាំងនោះឡើយ ។ សេចក្តីជូនដំណឹងបែបនេះ ត្រូវរួមបញ្ចូលនូវការធានា ចំពោះអ្នកស្នាក់នៅអចិន្ត្រៃយទាំងនោះ ឱ្យអនុលោមជាមួយច្បាប់ និងបទបញ្ញត្តិនានារបស់ខ្លួន ដូចគ្នានឹងការទទួលខុសត្រូវ ដែលភាគីដទៃទៀតប្រកាន់យកចំពោះពលរដ្ឋរបស់ខ្លួនដែរ

[9] នៅក្នុងករណីប្រទេសឥណ្ឌូនេស៊ី ឡាវ PDR ថៃឡង់ដ៍ វៀតណាម និង ប្រទេសចិន រូបវន្តបុគ្គល នៃភាគីដទៃទៀតត្រូវបានកំណត់ចំពោះរូបវន្តបុគ្គលដែលស្នាក់នៅក្នុងទឹកដីនៃភាគីទាំងនេះ ឬ កន្លែងណាមួយ និង ស្ថិតនៅក្រោមច្បាប់របស់ភាគីទាំងនោះ គឺជាអ្នកមានសញ្ជាតិនៃភាគីទាំងនោះ ។ ដូច្នេះស្ថិតក្រោមគោលការណ៍ នៃបទការព្រមព្រៀងនេះមិនត្រូវបានអនុវត្តចំពោះអ្នកស្នាក់នៅអចិន្ត្រៃនៃប្រទេសឥណ្ឌូនេស៊ី ឡាវ PDR ថៃឡង់ដ៍ វៀតណាម និង ប្រទេសចិន ។ ក្នុងករណីមួយចំនួនភាគីទាំងនេះបានអនុម័ត ច្បាប់ក្នុងប្រទេសរបស់គេស្តីពីប្រព្រឹត្តកម្មនៃអ្នកស្នាក់នៅអចិន្ត្រៃយ៍នៃភាគីដទៃ ឬ មិនមែនភាគីគួរត្រូវបានលើកឡើងថាតើត្រូវរួមបញ្ចូលអ្នកស្នាក់នៅអចិន្ត្រៃ ក្នុងភាពគ្រប់ដណ្តប់ នៃរូបវន្តបុគ្គលក្រោមកិច្ចព្រមព្រៀង នេះដោយគោរពទៅតាមភាគីនោះ ។

(ខ) "បុគ្គល" មានន័យដូចគ្នានឹងរូបវន្តបុគ្គល ឬ នីតិបុគ្គល ។

(ឈ) "វិស័យ" នៃសេវាកម្មមានន័យថា :

(i) សំដៅដល់ការសន្យាតាមវិស័យមួយ ដែលមានអនុវិស័យសេវាមួយ ឬច្រើន ឬទាំងអស់ នៃសេវាកម្មមួយនោះ ដូចមានចែងនៅក្នុងតារាងនៃការសន្យារបស់ភាគីមួយ

(ii) ក្រៅពីនេះ វិស័យសេវាកម្មទាំងមូលនោះ រួមបញ្ចូលទាំងអនុវិស័យទាំងអស់របស់វាផង ដែរ

(ញ) "សេវាកម្ម" រួមបញ្ចូលនូវសេវាណាមួយនៅក្នុងវិស័យណាមួយ ដោយលើកលែងតែសេវាដែលផ្តត់ផ្គង់សំរាប់អនុវត្តន៍កិច្ចការរបស់អាជ្ញាធររដ្ឋាភិបាលចេញ

(ត) "អ្នកប្រើប្រាស់សេវា" គឺជាបុគ្គលទាំងឡាយដែលទទួល ឬ ប្រើប្រាស់សេវាមួយ

(ថ) "សេវាកម្មរបស់ភាគីម្ខាងទៀត" មានន័យថា សេវាកម្មមួយដែលត្រូវបានផ្គត់ផ្គង់ :

(i) មកពី ឬ នៅក្នុងដែនដីរបស់ភាគីដទៃទៀត ឬ នៅក្នុងករណីដឹកជញ្ជូនផ្លូវសមុទ្រ ត្រូវបានផ្គត់ផ្គង់តាមរយៈនាវាដែលបានចុះបញ្ជីក្រោមច្បាប់របស់ភាគីដទៃទៀតនោះ ឬ ដោយបុគ្គលនៃភាគីដទៃទៀតនោះ ដែលផ្គត់ផ្គង់សេវាតាមរយៈប្រតិបត្តិការនាវា និង/ ឬ ប្រើប្រាស់ទាំងស្រុង ឬ ដោយផ្នែក នូវប្រតិបត្តិការនាវានោះ ឬ

(ii) ក្នុងករណីនៃការផ្គត់ផ្គង់សេវាតាមរយៈវត្តមានពាណិជ្ជកម្ម ឬតាមរយៈវត្តមានរូបវន្តបុគ្គលដោយអ្នកផ្គត់ផ្គង់សេវានៃភាគីដទៃទៀតនោះ

(ទ) "អ្នកផ្គត់ផ្គង់សេវា" មានន័យថា បុគ្គលណាម្នាក់ដែលធ្វើការផ្គត់ផ្គង់សេវា ។

(ធ) "ការផ្គត់ផ្គង់សេវា" រួមបញ្ចូលនូវ ផលិតកម្ម ការចែកចាយ ការស្វែងរកទីផ្សារ ការលក់ និងការផ្តល់សេវាមួយ ។

(ន) "ពាណិជ្ជកម្មសេវាកម្ម" ត្រូវបានកំណត់ថា ជាការផ្គត់ផ្គង់សេវា :

(i) ពីដែនដីនៃភាគីមួយទៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត "ផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន" ។

(ii) នៅក្នុងដែនដីនៃភាគីមួយទៅអ្នកប្រើប្រាស់សេវានៃភាគីណាមួយផ្សេងទៀត "ការប្រើប្រាស់នៅក្រៅប្រទេស" ។

(iii) ធ្វើឡើងដោយអ្នកផ្គត់ផ្គង់សេវានៃភាគីមួយ តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត "វត្តមានពាណិជ្ជកម្ម" ។

(iv) ធ្វើឡើងដោយអ្នកផ្គត់ផ្គង់សេវានៃភាគីមួយ តាមរយៈវត្តមានរូបវន្តបុគ្គលរបស់ ភាគីមួយនៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត "វត្តមានរូបវន្តបុគ្គល" ។

(ប) "នីតិវិធីចាំបាច់" មានន័យថា នីតិវិធីរដ្ឋបាលដែលមានការទាក់ទងនឹងការគ្រប់គ្រងតម្រូវការចាំបាច់នានា ។

(ផ) "ល័ក្ខខ័ណ្ឌតម្រូវការចាំបាច់" មានន័យថា ល័ក្ខខ័ណ្ឌតម្រូវការសំខាន់ទាំងឡាយណាដែលអ្នកផ្គត់ផ្គង់សេវាតម្រូវឱ្យបំពេញ ដើម្បីទទួលបានវិញ្ញាបនប័ត្រ ឬ អាជ្ញាប័ណ្ណ ។

## មាត្រា ២
## វិសាលភាព

១. កិច្ចព្រមព្រៀងនេះ អនុវត្តចំពោះវិធានការនានា ដែលចាត់ឡើងដោយភាគី ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ។

២. កិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះ :

(ក) សេវាកម្មដែលត្រូវបានផ្គត់ផ្គង់នៅក្នុងការអនុវត្តកិច្ចការ របស់អាជ្ញាធររដ្ឋាភិបាល នៅក្នុងដែនដីរបស់ភាគីនីមួយៗ ។

(ខ) បទប្បញ្ញត្តិ ឬ ល័ក្ខខ័ណ្ឌតម្រូវគ្រប់គ្រងលើលទ្ធកម្មដែលធ្វើឡើងដោយភ្នាក់ងាររដ្ឋាភិបាលក្នុងការទិញសេវាសំរាប់គោលបំណងបម្រើឱ្យរដ្ឋាភិបាល និង និងមិនមែនក្នុងគោលបំណងលក់បន្ត ឬប្រើប្រាស់សំរាប់ផ្គត់ផ្គង់សេវា ដើម្បីផលប្រយោជន៍ពាណិជ្ជកម្ម ។

# ជំពូក II : ការតព្វកិច្ច និង វិន័យ

## មាត្រា ៣
## តម្លាភាព

មាត្រា ៣ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ទោះជាមានការកែប្រែក៏ដោយ ក៏ត្រូវបានបញ្ចូល និងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះដែរ ។

## មាត្រា ៤
## ការផ្សព្វផ្សាយពត៌មានសម្ងាត់

មាត្រា ៣ ស្ទួន កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ទោះជាមានការកែប្រែក៏ដោយ ក៏ត្រូវបានបញ្ចូល និងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះដែរ ។

## មាត្រា ៥
## បទបញ្ញត្តិក្នុងស្រុក

១. នៅក្នុងវិស័យនានាដែលការសន្យាតាមវិស័យត្រូវបានធ្វើឡើងក្រោមផ្នែកទី ៣ គឺ ភាគីនីមួយៗ ត្រូវធានាថា វិធានការទាំងអស់នៃការអនុវត្តទូទៅដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ត្រូវបានចាត់ចែងក្នុងលក្ខណៈសមស្រប សត្យានុម័ត និងមិនលំអៀង ។

២. (ក) ភាគីនីមួយៗត្រូវរក្សា ឬបង្កើតឱ្យបានឆាប់តាមដែលអាចធ្វើបាន នូវនីតិវិធី ឬវេទិការមជ្ឈត្តការ ឬរដ្ឋបាល តាមសំណើរបស់អ្នកផ្គត់ផ្គង់សេវាដែលរងការប៉ះពាល់ ដើម្បីឱ្យមានការត្រួតពិនិត្យភ្លាមៗ លើបណ្តាសេចក្តីសម្រេចរដ្ឋបាលដែលបង្ការការជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ។ នៅពេលដែលនីតិវិធីទាំងនោះ មិនមានឯករាជ្យភាពពីភ្នាក់ងារសមត្ថកិច្ច ដែលចេញសេចក្តីសម្រេចរដ្ឋបាលដែលពាក់ព័ន្ធ ភាគីនោះត្រូវធានាថា នីតិវិធីទាំងនោះ នឹងត្រូវពិនិត្យឡើងវិញដោយសត្យានុម័ត និងមិនលំអៀង។

(ខ) បទបញ្ញត្តិទាំងឡាយនៃកថាខណ្ឌរង (ក) នឹងមិនត្រូវបកស្រាយ ដើម្បីតម្រូវឱ្យភាគីណាមួយបង្កើតវេទិកា ឬនីតិវិធីទាំងនោះ ដែលមិនស្របនឹងរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញ ឬសារជាតិនៃប្រព័ន្ធច្បាប់របស់ខ្លួនឡើយ ។

៣. នៅពេលដែលមានតម្រូវការការអនុញ្ញាតក្នុងការផ្គត់ផ្គង់សេវាកម្មមួយ ដែលមានការសន្យាជាក់លាក់ក្រោមកិច្ចព្រមព្រៀងនេះ ដែលបានធ្វើឡើង អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនីមួយៗត្រូវ :

(ក) តាមការស្នើសុំរបស់អ្នកដាក់ពាក្យស្នើសុំ ត្រូវកំណត់ពត៌មានបន្ថែមដែលចាំបាច់ទាំងឡាយ ដើម្បីបំពេញលើពាក្យសុំនោះ និងផ្តល់ឱកាសដល់ការធ្វើប្រាស្រ័យកែប្រែលើភាពខុសគ្នា ក្នុងអំឡុងពេលវេលាមួយសមស្រប ក្នុងករណីដែលអ្នកដាក់ពាក្យសុំនោះមិនបានបំពេញបែបបទពេញលេញ។

(ខ) តាមសំណើរបស់អ្នកស្នើសុំ ត្រូវផ្តល់ឱ្យដោយមិនមានការពន្យារពេលដែលមិនសមស្រប អំពីពត៌មានដែលពាក់ព័ន្ធនឹងស្ថានភាពនៃពាក្យសុំ និង

(គ) ប្រសិនបើពាក្យសុំត្រូវបានបញ្ចប់ ឬ បដិសេធ ទៅតាមលទ្ធភាពជាអតិបរមាដែលអាចធ្វើទៅបាន ត្រូវជូនដំណឹងដោយគ្មានការពន្យាពេលអំពីមូលហេតុនៃការសំរេចខាងលើទៅអ្នកស្នើសុំជាលាយល័ក្ខអក្សរ ។ អ្នកស្នើសុំនឹងមានលទ្ធភាពក្នុងការដាក់ពាក្យសុំជាថ្មីឡើងវិញទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។

៤. ក្នុងគោលបំណងដើម្បីធានាថា វិធានការទាំងឡាយដែលទាក់ទងទៅនឹងលក្ខខ័ណ្ឌចាំបាច់ នីតិវិធី និងបទដ្ឋានបច្ចេកទេស និងលក្ខខ័ណ្ឌចាំបាច់សំរាប់ផ្តល់អាជ្ញាប័ណ្ណ មិនត្រូវបានបង្កើតឡើងជារបាំងមិនចាំបាច់ចំពោះពាណិជ្ជកម្មសេវាកម្ម បណ្តាភាគីត្រូវរួមគ្នាពិនិត្យឡើងវិញនូវលទ្ធផលនៃការចរចា អំពីវិន័យលើវិធានការទាំងនោះ ដោយគោរពទៅតាមមាត្រា VI. ៤ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ក្នុងគោលបំណងបញ្ចូលលទ្ធផលទាំងនោះទៅក្នុងកិច្ចព្រមព្រៀងនេះ ។ បណ្តាភាគីបានកត់សំគាល់ថា វិន័យដែលបានដាក់ចុះទាំងនោះ គឺដើម្បីធានាដល់លក្ខខ័ណ្ឌចាំបាច់ក្នុងចំណោមនោះ ដោយ :

(ក) ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យជាសត្យានុម័ត និងតម្លាភាព ដូចជា សមត្ថភាព និងលទ្ធភាពក្នុងការផ្គត់ផ្គង់សេវា

(ខ) មិនដាក់បន្ទុកថែមទៀតលើសពីការចាំបាច់ ដើម្បីធានាគុណភាពសេវា

(គ) នៅក្នុងករណីនីតិវិធីផ្តល់អាជ្ញាប័ណ្ណ លក្ខខ័ណ្ឌតម្រូវទាំងនោះផ្ទាល់មិនត្រូវក្លាយជាការរឹតត្បិតលើការផ្គត់ផ្គង់សេវាឡើយ ។

៥. (ក) នៅក្នុងបណ្តាវិស័យដែលភាគីមួយបានសន្យាតាមវិស័យ ក្នុងផ្នែកទី III ដែលកម្មវត្ថុនៃការរួមបញ្ចូលនូវវិន័យដែលមានចែងនៅក្នុងកថាខ័ណ្ឌទី ៤ នៃកិច្ចព្រមព្រៀងនេះ ភាគីនោះមិនត្រូវអនុវត្តចេញអាជ្ញាប័ណ្ណ លក្ខខ័ណ្ឌចាំបាច់ និងបទដ្ឋានបច្ចេកទេសនានា ដែលធ្វើឱ្យមោឃៈភាព ឬបន្ថយនូវកាតព្វកិច្ចរបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ តាមលក្ខខ័ណ្ឌ :

(i) មិនស្របតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវាក្យខ័ណ្ឌរង៤ (ក) ,(ខ) ឬ (គ) នៃមាត្រានេះ និង

(ii) មិនអាចត្រូវបានរំពឹងទុកដោយសមហេតុផលពីសំណាក់ភាគីនោះ នៅខណៈពេលដែលការសន្យាតាមវិស័យទាំងនោះត្រូវបានធ្វើឡើង ។

(ខ) ក្នុងការកំណត់ ថាតើភាគីមួយអនុវត្តស្របតាមកាតព្វកិច្ចនៃកថាខ័ណ្ឌ ៥ (ក) នៃមាត្រានេះ ត្រូវពិចារណាលើបទដ្ឋានអន្តរជាតិនៃអង្គការអន្តរជាតិពាក់ព័ន្ធ ដែលភាគីនោះបានអនុវត្ត ។

៦. នៅក្នុងវិស័យដែលការសន្យាតាមវិស័យពាក់ព័ន្ធនឹងសេវាវិជ្ជាជីវៈត្រូវបានធ្វើឡើង ភាគីនីមួយៗ ត្រូវផ្តល់នីតិវិធីគ្រប់គ្រាន់ ដើម្បីផ្ទៀងផ្ទាត់សមត្ថភាពវិជ្ជាជីវៈនៃភាគីណាមួយផ្សេងទៀត ។

## មាត្រា ៦

## ការទទួលស្គាល់

១. សំរាប់គោលបំណងនៃការអនុវត្តទាំងស្រុង ឬដោយផ្នែកនូវបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យសំរាប់ការអនុញ្ញាតផ្តល់អាជ្ញាប័ណ្ណ ឬចេញវិញ្ញាបនប័ត្រដល់អ្នកផ្គត់ផ្គង់សេវា ភាគីនីមួយៗអាចទទួលស្គាល់ការសិក្សាអប់រំ ឬបទពិសោធន៍ដែលទទួលបាន ការបំពេញបានតាមលក្ខខ័ណ្ឌតម្រូវ ឬអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រ ដែលបានផ្តល់ជូនក្នុងប្រទេសរបស់ភាគីមួយទៀត ។ ការទទួលស្គាល់បែបនេះ អាចសំរេចបានតាមរយៈសុខដុមភាវូបនីយកម្ម ឬអាចផ្អែកលើកិច្ចព្រមព្រៀង ឬការរៀបចំរវាងបណ្តាភាគី ឬអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ឬត្រូវបានផ្តល់ជាស្វយ័តភាព ។

២. ភាគីពីរ ឬ ច្រើន អាចចូលរួម ឬជំរុញឱ្យអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ឱ្យចូលរួមធ្វើការចរចាស្តីពីការទទួលស្គាល់លើលក្ខខ័ណ្ឌចាំបាច់ នីតិវិធីចាំបាច់ ការចេញអាជ្ញាប័ណ្ណ និង/ឬ នីតិវិធីចុះបញ្ជី ដើម្បីបំពេញទៅតាមបទដ្ឋានចាំបាច់ ឬលក្ខណៈវិនិច្ឆ័យនីមួយៗ ចំពោះការផ្តល់សិទ្ធិ ការចេញអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រ ដល់អ្នកផ្គត់ផ្គង់សេវា ។

៣. ភាគីដែលជាភាគីមួយនៃកិច្ចព្រមព្រៀង ឬការរៀបចំដែលមានចែងក្នុងកថាខណ្ឌ១ ទោះជាកំពុងមានអត្ថិភាព ឬនឹងកើតមាននាពេលអនាគតក្តី ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីពាក់ព័ន្ធដទៃទៀត ដើម្បីអាចចូលរួមចរចាលើកិច្ចព្រមព្រៀង ឬការរៀបចំបែបនោះ ឬកិច្ចព្រមព្រៀង ឬការរៀបចំស្រដៀងគ្នា ។ នៅពេលណាដែលភាគីមួយ ផ្តល់ការទទួលស្គាល់ដោយស្វយ័តភាព ភាគីនោះត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដើម្បីឱ្យភាគីផ្សេងទៀតបង្ហាញថា ការសិក្សាអប់រំ បទពិសោធន៍ អាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រដែលទទួលបាន ឬដែលបំពេញបានតាមលក្ខខណ្ឌតំរូវនៅក្នុងដែនដីរបស់ភាគីដទៃទៀត ក៏នឹងត្រូវបានទទួលស្គាល់ផងដែរ ។

៤. ភាគីមួយមិនត្រូវផ្តល់ការទទួលស្គាល់ក្នុងលក្ខណៈមួយ ដែលនឹងបង្កើតឱ្យមានការរើសអើងរវាងប្រទេសនានា នៅក្នុងការអនុវត្តបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យរបស់ខ្លួន សម្រាប់ការផ្តល់ការអនុញ្ញាតចេញអាជ្ញាប័ណ្ណ ឬវិញ្ញាបនប័ត្រដល់អ្នកផ្គត់ផ្គង់សេវា ឬការរិតត្បិតជាលក្ខណៈបិទបាំងលើពាណិជ្ជកម្មសេវាកម្ម ឡើយ ។

## មាត្រា ៧
## ភាពផ្តាច់មុខ និងអ្នកផ្គត់ផ្គង់សេវាផ្តាច់មុខ

១. ភាគីនីមួយៗត្រូវធានាថា អ្នកផ្គត់ផ្គង់សេវាផ្តាច់មុខណាមួយនៅក្នុងដែនដីរបស់ខ្លួន នៅក្នុងការផ្គត់ផ្គង់សេវាផ្តាច់មុខក្នុងទីផ្សារពាក់ព័ន្ធនានា នឹងមិនប្រព្រឹត្តក្នុងលក្ខណៈមួយដែលមិនស្របតាមកាតព្វកិច្ចរបស់ខ្លួន ដោយអនុលោមតាមការសន្យាតាមវិស័យឡើយ។

២. នៅពេលដែលអ្នកផ្គត់ផ្គង់ផ្តាច់មុខរបស់ភាគីមួយ ប្រកួតប្រជែងដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនសម្ព័ន្ធភាព ក្នុងការផ្គត់ផ្គង់សេវាដែលស្ថិតក្រៅវិសាលភាពនៃសិទ្ធិផ្តាច់មុខរបស់ខ្លួន និងដែលជាកម្មវត្ថុនៃការសន្យាតាមវិស័យរបស់ភាគីនោះ ភាគីនោះត្រូវធានាថា អ្នកផ្គត់ផ្គង់នេះ នឹងមិនអនុវត្តបំពានទូវតួនាទីផ្តាច់មុខរបស់ខ្លួន ក្នុងការផ្គត់ផ្គង់នៅក្នុងដែនដីរបស់ភាគី ក្នុងលក្ខណៈមួយដែលមិនសមស្របនឹងការសន្យាទាំងនោះ។

៣. ប្រសិនបើភាគីណាមួយមានមូលហេតុដែលគួរឱ្យជឿថា អ្នកផ្គត់ផ្គង់សេវាផ្តាច់មុខនៃភាគីមួយផ្សេងទៀត កំពុងតែប្រព្រឹត្តមិនស្របនឹងកថាខណ្ឌ១ ឬ២ នៃមាត្រានេះ ភាគីនោះអាចស្នើភាគីដែលបង្កើត រក្សាទុក ឬអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់សេវានោះ ផ្តល់ពត៌មានជាក់លាក់អំពីប្រតិបត្តិការពាក់ព័ន្ធរបស់ខ្លួនបាន។

៤. បទប្បញ្ញត្តិនានានៃមាត្រានេះ ក៏ត្រូវអនុវត្តផងដែរ ចំពោះករណីដែលអ្នកផ្គត់ផ្គង់សេវាផ្តាច់មុខទាំងឡាយ ដែលភាគីមួយជាផ្លូវការ ឬជាឥទ្ធិពលៈ

(ក) អនុញ្ញាត ឬបង្កើតឱ្យមានអ្នកផ្គត់ផ្គង់សេវាមួយក្រុមតូច និង

(ខ) រារាំងស្ទើរតែទាំងស្រុងមិនឱ្យមានការប្រកួតប្រជែងក្នុងចំណោមអ្នកផ្គត់ផ្គង់ទាំងនោះ នៅក្នុងដែនដីរបស់ខ្លួន។

## មាត្រា ៨
## ការអនុវត្តធុរកិច្ច

១. បណ្តាភាគីទទួលស្គាល់ថា ការអនុវត្តធុរកិច្ចមួយចំនួនរបស់អ្នកផ្គត់ផ្គង់សេវា ក្រៅពីការអនុវត្តដែលមានចែងក្នុងមាត្រា ៧ អាចបន្ថយបង្អាក់ការប្រកួតប្រជែង និងដោយសារហេតុផលនេះហើយ ដែលធ្វើឱ្យមានការរឹតត្បិតពាណិជ្ជកម្មសេវាកម្ម។

២. ភាគីនីមួយៗ តាមសំណើរបស់ភាគីណាមួយផ្សេងទៀត ("ភាគីស្នើសុំ") ត្រូវចូលរួមពិគ្រោះយោបល់ ក្នុងគោលបំណងដើម្បីលុបបំបាត់ការអនុវត្តនានាដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។ ភាគីដែលត្រូវបានស្នើសុំនោះ ត្រូវពិចារណាឱ្យបានពេញលេញ និងប្រកបដោយសមានចិត្តចំពោះសំណើបែបនេះ និងត្រូវធ្វើសហប្រតិបត្តិការ តាមរយៈ ការផ្តល់ពត៌មានមិនសំងាត់ ដែលអាចរកបានជាសាធារណៈទាក់ទិននឹងបញ្ហាដែលជាកម្មវត្ថុនោះ។ ភាគីដែលត្រូវបានស្នើសុំ ក៏ត្រូវផ្តល់ផងដែរនូវពត៌មាន ដែលអាចរកបានដទៃទៀត តាមសំណើរបស់ភាគីស្នើសុំផ្អែកតាមច្បាប់ក្នុងស្រុករបស់ភាគីនោះ និងអាស្រ័យលើការព្រមព្រៀងគ្នាស្តីពីកិច្ចការពារការសំងាត់របស់ភាគីស្នើសុំ។

## មាត្រា ៩
## ការការពារ

១. បណ្តាភាគីកត់សំគាល់អំពីកិច្ចចរចាពហុភាគី អនុលោមតាមមាត្រា X នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម លើបញ្ហាវិធានការការពារក្នុងសភាពអាសន្ន ផ្អែកលើគោលការណ៍មិនរើសអើង។ នៅពេលបញ្ចប់កិច្ចចរចាពហុភាគីទាំងនោះ បណ្តាភាគីត្រូវធ្វើការពិនិត្យឡើងវិញ សំដៅពិភាក្សាអំពីការធ្វើវិសោធនកម្មសមស្រប ចំពោះកិច្ចព្រមព្រៀងនេះ ដើម្បីបញ្ចូលលទ្ធផលនៃកិច្ចចរចារពហុភាគីនោះ។

២. នៅក្នុងករណីដែលការអនុវត្តកិច្ចព្រមព្រៀងនេះបណ្តាលឱ្យកើតមានផលប៉ះពាល់ធ្ងន់ធ្ងរទៅដល់វិស័យសេវាកម្មរបស់ភាគីមួយ នៅមុនការបញ្ចប់កិច្ចចរចាពហុភាគី ដែលយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ភាគីដែលរងការប៉ះពាល់ អាចស្នើសុំឱ្យមានកិច្ចពិគ្រោះយោបល់ជាមួយភាគីដទៃទៀត ដើម្បីពិភាក្សាអំពីការចាត់វិធានការ លើវិស័យសេវាកម្មដែលរងការប៉ះពាល់នោះ។ វិធានការណាមួយក៏ដោយ ដែលចាត់ឡើងអនុលោមតាមកថាខណ្ឌនេះ ត្រូវតែមានការព្រមព្រៀងគ្នាទៅវិញទៅមកដោយភាគីពាក់ព័ន្ធ។ បណ្តាភាគីពាក់ព័ន្ធត្រូវយកមកពិចារណានូវកាលៈទេសៈនៃករណីជាក់ស្តែងនីមួយៗ និងផ្តល់នូវការពិចារណាប្រកបដោយសមានចិត្តចំពោះភាគីដែលស្នើសុំឱ្យចាត់វិធានការ។

## មាត្រា ១០
## ការទូទាត់ និងការផ្ទេរ

១. លើកលែងតែស្ថិតក្រោមកាលៈទេសៈដែលបានប្រមើទុក នៅក្នុងមាត្រា ១១ ភាគីមួយមិនត្រូវដាក់ការរិតត្បិតចំពោះការផ្ទេរ និងទូទាត់អន្តរជាតិ សម្រាប់ប្រតិបត្តិការចរន្តទាំងឡាយដែលទាក់ទិននឹងការសន្យាតាមវិស័យរបស់ខ្លួនឡើយ។

២. គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ ដែលនឹងត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីណាមួយ ដែលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ អនុលោមតាមកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ រួមបញ្ចូលទាំងការប្រើប្រាស់សកម្មភាពដោះដូរដោយអនុលោមតាមកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ ឱ្យតែភាគីនោះមិនដាក់ការរឹតត្បិត លើប្រតិបត្តិការមូលធនណាមួយ ផ្ទុយពីការសន្យាតាមវិស័យរបស់ខ្លួន ពាក់ព័ន្ធនឹងប្រតិបត្តិការនោះ លើកលែងតែការរឹតត្បិតក្រោមមាត្រា ១១ ឬផ្នែកតាមសំណើរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

## មាត្រា ១១
## ការរឹតត្បិតដើម្បីការពារជញ្ជីងទូទាត់

នៅពេលណាដែលភាគីមួយមានស្ថានភាពជញ្ជីងទូទាត់ធ្ងន់ធ្ងរ និងជួបការលំបាកខាងហិរញ្ញវត្ថុក្រៅប្រទេស ឬមានការគំរាមកំហែងពីស្ថានការណ៍បែបនោះ ភាគីនោះអាចអនុម័ត ឬរក្សាការរឹតត្បិត ចំពោះពាណិជ្ជកម្មសេវាកម្ម ដោយអនុលោមតាមមាត្រា XII របស់កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ។

## មាត្រា ១២
## ការលើកលែងទូទៅ

យោងតាមលក្ខខ័ណ្ឌតម្រូវដែលវិធានការបែបនេះ មិនត្រូវបានអនុវត្តក្នុងលក្ខណៈមួយដែលនឹងនាំឱ្យមានការរើសអើងដោយមិនស្មើភាព ឬគ្មានយុត្តិកម្មរវាងបណ្តាភាគីដែលមានលក្ខខ័ណ្ឌដូចគ្នា ឬរឹតត្បិតពាណិជ្ជកម្មសេវាកម្មដោយបិទបាំង គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះដែលនឹងត្រូវបកស្រាយដើម្បីធ្វើការរារាំងដល់ការអនុម័ត ឬការអនុវត្តដោយភាគីណាមួយនូវបណ្តាវិធានការដែល:

ក. ចាំបាច់សម្រាប់ការពារសីលធម៌សាធារណៈ ឬដើម្បីថែរក្សាសណ្តាប់ធ្នាប់សាធារណៈ

ខ. ចាំបាច់សំរាប់ការពារជីវិត ឬ សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ

គ. ចាំបាច់សំរាប់ធានាឱ្យមានភាពស្របតាមច្បាប់ ឬបទបញ្ជាទាំងឡាយដែលមិនផ្ទុយពីបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ រួមបញ្ចូលនូវអ្វីៗដែលពាក់ព័ន្ធនឹង :

(i) ការទប់ស្កាត់ការអនុវត្តបែបឆបោក និងទុច្ចរិត ឬចាត់វិធានការទល់នឹងការខកខានមិនបានបំពេញតាមកិច្ចសន្យាសេវាកម្ម ។

(ii) ការការពារជីវិតឯកជននៃបុគ្គលម្នាក់ៗទាក់ទិននឹងការស្វែងរក និងផ្សព្វផ្សាយទិន្នន័យផ្ទាល់ខ្លួន និងការការពារការសំងាត់នៃប្រវត្តិរូប និងគណនីផ្ទាល់ខ្លួន ។

(iii) សុវត្ថិភាព ។

ឃ. មិនអនុលោមតាមមាត្រា ១៩ លើកលែងតែប្រព្រឹត្តិកម្មខុសគ្នាធ្វើឡើងសំដៅ ធានាបាននូវការកំណត់ ឬប្រមូលពន្ធផ្ទាល់ប្រកបដោយសមធម៌ ឬមានប្រសិទ្ធភាព ពីសេវាកម្ម និងអ្នកផ្គត់ផ្គង់សេវារបស់ភាគីដទៃទៀត ។

ង. ដោយមានប្រព្រឹត្តិកម្មខុសគ្នា លើកលែងតែមានកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធទ្វេដង ឬ ដោយសារបទប្បញ្ញត្តិមួយចំនួនស្តីពីការចៀសវាងការយកពន្ធទ្វេដង ទៅក្នុងកិច្ចព្រមព្រៀង ឬការរៀបចំអន្តរជាតិផ្សេងៗទៀត ដែលភាគីនោះត្រូវជាប់កាតព្វកិច្ច ។

## មាត្រា ១៣
## ការលើកលែងផ្នែកសន្តិសុខ

១. គ្មានអ្វីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវបកស្រាយដើម្បី :

ក. តម្រូវឱ្យភាគីណាមួយផ្តល់ពត៌មានទាំងឡាយ ដែលការទម្លាយពត៌មាននោះត្រូវបានគិតថាផ្ទុយនឹងផលប្រយោជន៍សន្តិសុខជាសារវន្តរបស់ភាគីនោះ ឬ

ខ. រារាំងភាគីណាមួយមិនឱ្យចាត់វិធានការនានាដែលគិតថាចាំបាច់សំរាប់ការពារផលប្រយោជន៍ សន្តិសុខរបស់ខ្លួន ដែលរួមមាន ប៉ុន្តែមិនកំហិតត្រឹមតែ :

(i) សកម្មភាពទាក់ទិននឹងសម្ភារៈដែលអាចបំបែក ឬរំលាយបញ្ចូលគ្នាបាន ឬ សម្ភារៈនានាដែលកើតចេញពីសារធាតុទាំងនោះ

(ii) សកម្មភាពទាក់ទងនឹងការធ្វើចរាចរសព្វាវុធ គ្រាប់រំសេវ និងសម្ភារៈសង្គ្រាម និងការចរាចរនូវទំនិញ និងវត្ថុធាតុផ្សេងៗនៅក្នុងអនុវត្តដោយផ្ទាល់ ឬប្រយោល ដើម្បីផ្គត់ផ្គង់ដល់ទីតាំងយោធា ។

(iii) សកម្មភាពដែលធ្វើឡើងសំដៅការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាអាយុជីវិត រួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ទឹក និងថាមពល ពីការប៉ុនប៉ងធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធទាំងនោះ

(iv) សកម្មភាពដែលធ្វើឡើងក្នុងពេលមានសង្គ្រាម ឬសភាពអាសន្នក្នុងទំនាក់ទំនងស្រុក ឬ អន្តរជាតិ ឬ

គ. រារាំងសមាជិកនានាមិនឱ្យចាត់វិធានការណាមួយ ស្របតាមកាតព្វកិច្ចរបស់ខ្លួនតាមធម្មនុញ្ញអង្គការសហប្រជាជាតិ សំរាប់កិច្ចថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ។

## មាត្រា ១៤

## ឧបត្ថម្ភធន

១. លើកលែងតែមានចែងនៅក្នុងមាត្រានេះ កិច្ចព្រមព្រៀងនេះមិនត្រូវអនុវត្តចំពោះឧបត្ថម្ភធន ឬ ជំនួយផ្សេងៗផ្តល់ដោយភាគីមួយ ឬចំពោះលក្ខខ័ណ្ឌណាមួយដែលភ្ជាប់ជាមួយនឹងការទទួល ឬការបន្តទទួលនូវឧបត្ថម្ភធន ឬជំនួយបែបនេះឡើយ ទោះបីជាឧបត្ថម្ភធន ឬជំនួយទាំងនោះត្រូវបានផ្តល់ផ្ទាល់ មុខ ឬមិនផ្ទាល់មុខចំពោះសេវាកម្មក្នុងស្រុក អ្នកប្រើប្រាស់សេវា ឬអ្នកផ្គត់ផ្គង់សេវាក៏ដោយ ។ ប្រសិនបើឧបត្ថម្ភធន ឬជំនួយទាំងនោះ ជះឥទ្ធិពលធំធេងដល់ពាណិជ្ជកម្មសេវាកម្ម ដែលបានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីនានាអាចស្នើសុំពិគ្រោះយោបល់ ដើម្បីរកដំណោះស្រាយប្រកបដោយមិត្តភាពចំពោះបញ្ហានេះ ។

២. អនុលោមតាមកិច្ចព្រមព្រៀងនេះ បណ្តាភាគីត្រូវ :

ក. ផ្អែកតាមការស្នើសុំ ត្រូវផ្តល់ពត៌មានស្តីពីឧបត្ថម្ភធនទាក់ទិននឹងពាណិជ្ជកម្មសេវាកម្ម ដែលបានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ជូនដល់ភាគីស្នើសុំ និង

ខ. ពិនិត្យឡើងវិញនូវប្រព្រឹត្តិកម្មនៃឧបត្ថម្ភធន នៅពេលណាវិន័យពាក់ព័ន្ធនានាត្រូវបានបង្កើតឡើងដោយអង្គការពាណិជ្ជកម្មពិភពលោក ។

## មាត្រា ១៥

## វិន័យអង្គការពាណិជ្ជកម្មពិភពលោក

អាស្រ័យលើកិច្ចព្រមព្រៀងអនាគតណាមួយ ដែលអាចត្រូវបានព្រមព្រៀងគ្នាអនុលោមតាមការពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងនេះ ដោយបណ្តាភាគីតាមមាត្រា ២៧ បណ្តាភាគីនៅពេលនេះព្រមព្រៀង និងអះអាងជាថ្មីអំពីការប្តេជ្ញារបស់ខ្លួនក្នុងការគោរពតាមបទប្បញ្ញត្តិនានា នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដែលពាក់ព័ន្ធ និងដែលអាចអនុវត្តបានចំពោះពាណិជ្ជកម្មសេវាកម្ម ។

## មាត្រា ១៦
## សហប្រតិបត្តិការ

ភាគីទាំងអស់ត្រូវខិតខំពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យសេវាកម្ម រួមទាំងវិស័យនានាដែលមិនគ្រប ដណ្តប់ដោយការរៀបចំសហប្រតិបត្តិការដែលមាន ។ បណ្តាភាគីត្រូវពិភាក្សា និងព្រមព្រៀងទៅវិញទៅមក លើវិស័យនានាសំរាប់កិច្ចសហប្រតិបត្តិការ និងបង្កើតកម្មវិធីសហប្រតិបត្តិការនៅក្នុងវិស័យទាំងនោះ ដើម្បីបង្កើន សមត្ថភាព ប្រសិទ្ធភាព និងភាពប្រកួតប្រជែងក្នុងស្រុក ។

## មាត្រា ១៧
## បង្កើនការចូលរួមរបស់កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម

ការបង្កើនការចូលរួមរបស់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម នៅក្នុងពាណិជ្ជកម្មសេវាកម្ម ត្រូវបានសម្រួលតាមរយៈការសន្យាតាមវិស័យដែលបានចរចារួច ទាក់ទិននឹង :

ក. ការពង្រឹងសមត្ថភាពសេវាកម្មក្នុងស្រុករបស់ពួកគេ និងប្រសិទ្ធភាព និងភាពប្រកួតប្រជែងរបស់ សេវា ក្នុងចំណោមនោះ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាលើមូលដ្ឋានពាណិជ្ជកម្ម

ខ. ការកែលំអការចូលរួមប្រើប្រាស់ខ្សែសង្វាក់ចែកចាយ និងបណ្តាញពត៌មាន

គ. សេរីភាវូបនីយកម្មច្រកចូលទីផ្សារនៃវិស័យ និងរបៀបនៃការផ្គត់ផ្គង់សេវាដែលមានអត្ថប្រយោ- ជន៍សម្រាប់ការនាំចេញរបស់ពួកគេ និង

ឃ. ផ្តល់ភាពទន់ភ្លន់សមស្របដល់ប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម ដើម្បីចរចាបើក ទូលាយវិស័យក្នុងចំនួនតិចជាង ធ្វើសេរីភាវូបនីយកម្មប្រភេទប្រតិបត្តិការក្នុងចំនួនតិចជាង និង បើកច្រកចូលទីផ្សារជាបណ្តើរៗ អាស្រ័យតាមស្ថានភាពនៃការអភិវឌ្ឍន៍របស់ប្រទេសនីមួយៗ ។

## ជំពូក III ការសន្យាតាមវិស័យ
## មាត្រា ១៨
## ការបើកច្រកទីផ្សារ

១. ចំពោះច្រកចូលទីផ្សារតាមរយៈរបៀបនៃការផ្គត់ផ្គង់សេវាដែលមានចែងក្នុងមាត្រា១ (ឌ)(i)-(iv) ភាគី ត្រូវផ្តល់ដល់សេវា និងអ្នកផ្គត់ផ្គង់សេវារបស់ភាគីផ្សេងទៀត នូវប្រព្រឹត្តិកម្មមិនមានភាពអនុគ្រោះតិច

ជាងអ្វីដែលបានកំណត់នៅក្នុងលក្ខខ័ណ្ឌដែនកំណត់ និងលក្ខខ័ណ្ឌនានាដែលបានព្រមព្រៀងគ្នា និងដែលមានចែងនៅក្នុងតារាងនៃការសន្យារបស់ខ្លួនឡើយ ។

២. នៅក្នុងវិស័យទាំងឡាយដែលការសន្យាប្រកចូលទីផ្សារ ត្រូវបានធ្វើឡើង វិធានការនានាដែលភាគីមួយមិនត្រូវរក្សាទុក ឬអនុម័តយកមកប្រើប្រាស់ ទោះក្នុងមូលដ្ឋាននៃផ្នែកតូចៗនៃតំបន់ ឬក្នុង ក្របខ័ណ្ឌដែនដីទាំងមូលរបស់ខ្លួនក្តី លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងតារាងនៃការសន្យាតាមវិស័យរបស់ខ្លួន បើមិនដូច្នោះទេ ត្រូវបានកំណត់ដូចខាងក្រោម :

(ក) ការកំណត់លើចំនួនអ្នកផ្គត់ផ្គង់សេវា ទោះជាក្នុងទម្រង់ចំនួនកូតា ភាពផ្តាច់មុខ អ្នកផ្គត់ផ្គង់សេវាផ្តាច់មុខ ឬលក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច

(ខ) ដាក់ការកំណត់លើតម្លៃសរុបនៃប្រតិបត្តិការសេវាកម្ម ឬទ្រព្យសម្បត្តិ ក្នុងទម្រង់បរិមាណកូតា ឬ លក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច

(គ) ដាក់ការរឹតត្បិតលើបរិមាណសរុបនៃប្រតិបត្តិការសេវាកម្ម ឬលើបរិមាណសរុបនៃទិន្នផលសេវាកម្ម គិតជាឯកតាលេខនព្វន្តក្នុងទម្រង់កូតា ឬលក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច ។

(ឃ) ដាក់ការកំណត់បរិមាណសរុបនៃរូបវន្តបុគ្គល ដែលអាចជួលមកធ្វើការនៅក្នុងវិស័យសេវាកម្មណាមួយ ឬការកំណត់លើរូបវន្តបុគ្គលដែលអ្នកផ្គត់ផ្គង់សេវាអាចជួលមកធ្វើការ និងរូបវន្តបុគ្គលដែលចាំបាច់ និងមានការទាក់ទិនផ្ទាល់ទៅនឹងការផ្គត់ផ្គង់សេវាណាមួយ ក្នុងទំរង់បរិមាណកូតា ឬលក្ខខ័ណ្ឌតម្រូវនៃតម្រូវការសេដ្ឋកិច្ច

(ង) វិធានការទាំងឡាយដែលរឹតត្បិត ឬតម្រូវឱ្យមានប្រភេទនីតិបុគ្គលណាមួយ ឬត្រូវចម្រុះទុនដែលតាមរយៈនោះ អ្នកផ្គត់ផ្គង់សេវាធ្វើការផ្គត់ផ្គង់សេវាបាន និង

(ច) ដាក់ការកំណត់លើចំណែកមូលធនបរទេសក្នុងន័យជាការកំណត់អត្រាភាគរយអតិបរមាសម្រាប់ភាគទុនបរទេស ឬលើតម្លៃសរុបនៃវិនិយោគបរទេសនីមួយៗ ឬលើតម្លៃសរុប នៃវិនិយោគបរទេសសរុប ។

## មាត្រា ១៩
## ប្រព្រឹត្តិកម្មជាតិ

១. នៅក្នុងវិស័យនានាដែលមានចែងក្នុងតារាងនៃការសន្យារបស់ខ្លួន និងអាស្រ័យតាមបណ្តាលក្ខខណ្ឌ និងគុណវុឌ្ឍិកម្មដែលចែងក្នុងនោះ ភាគីនីមួយៗត្រូវផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវា នៃភាគីផ្សេង

ទៀតពាក់ព័ន្ធនឹងវិធានការទាំងអស់ ដែលជះឥទ្ធិពលដល់ការផ្គត់ផ្គង់សេវានូវប្រព្រឹត្តិកម្ម មិនមានភាពអនុគ្រោះតិចជាងអ្វី ដែលបានផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវាដូចគ្នារបស់ប្រទេសខ្លួនឡើយ ។

២. ភាគីមួយអាចបំពេញបានតាមលក្ខខ័ណ្ឌតម្រូវនៃកថាខ័ណ្ឌ១ នៃមាត្រានេះ តាមរយៈការផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវានៃភាគីដទៃទៀត នូវប្រព្រឹត្តិកម្មដូចគ្នា ឬខុសគ្នាទៅនឹងប្រព្រឹត្តិកម្មផ្តល់ដល់សេវាកម្ម និងអ្នកផ្គត់ផ្គង់សេវា ដូចគ្នារបស់ជាតិខ្លួនផ្ទាល់ ។

៣. ប្រព្រឹត្តិកម្មដូចគ្នា ឬខុសគ្នា ត្រូវបានចាត់ទុកថា មានភាពអនុគ្រោះតិចជាង ប្រសិនបើវាបានកែប្រែលក្ខខ័ណ្ឌប្រកួតប្រជែង ដោយផ្តល់ផលប្រយោជន៍ចំពោះសេវាកម្ម និងអ្នកផ្គត់ផ្គង់សេវារបស់ភាគីមួយ ធៀបនឹងសេវាកម្ម ឬអ្នកផ្គត់ផ្គង់សេវាដូចគ្នានៃភាគីមួយផ្សេងទៀត ។

## មាត្រា ២០
## ការសន្យាបន្ថែម

បណ្តាភាគីអាចចរចាលើការសន្យាដែលពាក់ព័ន្ធនឹងវិធានការនានា ដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ដែលមិនមែនជាកម្មវត្ថុការដាក់ចូលក្នុងតារាងនៃការសន្យាធ្វើឡើងនៅក្រោមមាត្រា១៨ ឬមាត្រា១៩ រួមបញ្ចូលនូវវិធានការនានាពាក់ព័ន្ធនឹងគុណវុឌ្ឍិ ស្តង់ដារ ឬអាជ្ញាប័ណ្ណ ។ ការសន្យាទាំងនេះត្រូវសរសេរនៅក្នុងតារាងនៃការសន្យារបស់ភាគី ។

## មាត្រា ២១
## តារាងសន្យាតាមវិស័យ

១. ភាគីទាំងអស់ត្រូវចូលរួមចរចា ដើម្បីសម្រេចនូវកញ្ចប់នៃការសន្យាតាមវិស័យ អនុលោមតាមមាត្រា ២៣ នៃកិច្ចព្រមព្រៀងនេះ ។ បណ្តាភាគីត្រូវខិតខំដើម្បីសម្រេចនូវការសន្យាឱ្យលើសពីការដែលខ្លួនបានសន្យាក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ។

២. ភាគីនីមួយៗ ត្រូវធ្វើតារាងសន្យាតាមវិស័យមួយ ដែលខ្លួនបានព្រមព្រៀងក្រោមមាត្រា ១៨-១៩ និង ២០ ។ ចំពោះវិស័យដែលខ្លួនបានសន្យារួចហើយ តារាងនីមួយៗត្រូវបញ្ជាក់ :

(ក) វិស័យនានាដែលបានសន្យា

(ខ) លក្ខខ័ណ្ឌ ការកំណត់ និងលក្ខខ័ណ្ឌស្តីពីការបើកច្រកទីផ្សារសេវាកម្ម

(គ) លក្ខខ័ណ្ឌ និង លក្ខខ័ណ្ឌចាំបាច់ស្តីពីប្រព្រឹត្តិកម្មជាតិ

(ឃ) ការទទួលយកដែលទាក់ទងនឹងការសន្យាបន្ថែម និង

(ង) ការកំណត់ពេលវេលាសមស្របសំរាប់អនុវត្ត នៃកិច្ចសន្យាទាំងនោះ

៣. វិធានការនានាដែលមិនស្របទឹងមាត្រា ១៨ និង ១៩ ត្រូវចុះក្នុងតារាងទាំងពីរដែលមានទាក់ទងទៅនឹង មាត្រា ១៨-១៩ ។

៤. តារាងនៃការសន្យាតាមវិស័យរបស់ភាគីមួយ ត្រូវអនុវត្តតែចំពោះភាគីទាំងនោះដែលបានបំពេញរួចរាល់ នូវតារាងនៃការសន្យាតាមវិស័យរបស់ខ្លួនតាមរយៈការចរចា ។

៥. តារាងនៃការសន្យាតាមវិស័យរបស់បណ្តាភាគី ត្រូវភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ នៅពេល ការចរចាត្រូវបានសម្រេច និង ត្រូវបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀង ពីពេលនោះ ។

## មាត្រា ២២
## ការអនុវត្ត និងការផ្តល់ការសន្យា

១. ភាគីចិនត្រូវបង្កើតតារាងនៃការសន្យាតាមវិស័យតែមួយគត់តាមមាត្រា ២១ ហើយត្រូវអនុវត្តតារាងនៃការ សន្យានេះ ចំពោះប្រទេសសមាជិកអាស៊ានទាំងអស់ ។

២. ប្រទេសសមាជិកអាស៊ាននីមួយៗ ត្រូវបង្កើតតារាងនៃការសន្យាតាមវិស័យរៀងៗខ្លួន តាមមាត្រា ២២ និង ត្រូវអនុវត្តតារាងនៃការសន្យានេះចំពោះភាគីចិន និងសមាជិកអាស៊ានដទៃទៀត ។

## មាត្រា ២៣
## ការធ្វើសេរីភាវូបនីយកម្មជាបណ្តើរៗ

១. កញ្ចប់ដំបូងនៃការសន្យាតាមវិស័យរបស់ភាគីនីមួយៗ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ។

២. ក្នុងគោលបំណងដើម្បីបង្កើនការសម្រេចកញ្ចប់ទី១ នៃការសន្យាតាមវិស័យ បណ្តាភាគីត្រូវសម្រេចនូវ កញ្ចប់ទី២នៃការសន្យាតាមវិស័យក្នុងរយៈពេល១ឆ្នាំ ចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ។

៣. ការពិនិត្យឡើងវិញជាបន្តបន្ទាប់ទៅតាមមាត្រា ២៧ បណ្តាភាគីត្រូវចូលរួមកិច្ចចរចា ដើម្បីសម្រេចនូវកញ្ចប់ការសន្យាតាមវិស័យបន្ថែមទៀត តាមផ្នែកទី ៣ នៃកិច្ចព្រមព្រៀងនេះ ដើម្បីបន្តធ្វើសេរីភាវូបនីយកម្មបណ្តើរៗ ចំពោះពាណិជ្ជកម្មសេវាកម្មរវាងបណ្តាភាគី ។

## មាត្រា ២៤
## ការកែប្រែតារាងការសន្យា

១. ភាគីមួយអាចកែប្រែ ឬដកចេញនូវការសន្យាណាមួយនៅក្នុងតារាងនៃការសន្យារបស់ខ្លួននៅពេលណាមួយក៏បាន បន្ទាប់ពីរយៈពេលបីឆ្នាំបានកន្លងផុតទៅ គិតចាប់ពីកាលបរិច្ឆេទដែលការសន្យានោះបានចូលជាធរមាន ឱ្យតែ :

(ក) ភាគីនោះជូនដំណឹងដល់បណ្តាភាគី និងលេខាធិការដ្ឋានអាស៊ានអំពីចេតនារបស់ខ្លួនក្នុងការកែប្រែឬដកចេញនូវការសន្យាមិនហួសពីបីខែមុនកាលបរិច្ឆេទ ដើម្បីចាប់ផ្តើមអនុវត្តការកែប្រែ ឬដកចេញរបស់ខ្លួន និង

(ខ) ភាគីនោះចូលរួមចរចាជាមួយភាគីរងការប៉ះពាល់ ដើម្បីព្រមព្រៀងគ្នាអំពីសំណងទូទាត់ចាំបាច់ ។

២. ដើម្បីសម្រេចបាននូវសំណងទូទាត់មួយ បណ្តាភាគីត្រូវធានាថា កម្រិតទូទៅនៃការសន្យាដែលមានផលប្រយោជន៍ទៅវិញទៅមកមិនត្រូវមានភាពអនុគ្រោះចំពោះពាណិជ្ជកម្មតិចជាងអ្វីដែលបានផ្តល់នៅក្នុងតារាងនៃការសន្យា ដែលមានមុនពេលចាប់ផ្តើមចរចាបែបនេះ ឡើយ ។

៣. សំណងទូទាត់ណាមួយដែលធ្វើឡើងស្របតាមមាត្រានេះ នឹងត្រូវផ្តល់ជូនលើមូលដ្ឋានមិនរើសអើងចំពោះភាគីទាំងអស់ ។

៤. ប្រសិនបើភាគីពាក់ព័ន្ធមិនអាចសម្រេចបាននូវកិច្ចព្រមព្រៀងស្តីពីសំណងទូទាត់ណាមួយទេនោះ បញ្ហានេះនឹងត្រូវដោះស្រាយដោយមជ្ឈត្តការ អនុលោមតាមកិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។ ភាគីដែលស្នើកែប្រែ មិនត្រូវអនុវត្តការកែប្រែ ឬដកចេញការសន្យារបស់ខ្លួនឡើយ ដោយត្រូវរង់ចាំរហូតភាគីនោះបានធ្វើសំណងទូទាត់ស្របតាមការសម្រេចរបស់មជ្ឈត្តការរួចរាល់សិន ។

៥. ប្រសិនបើភាគីកែប្រែ អនុវត្តគំរោងកែប្រែ ឬដកចេញការសន្យារបស់ខ្លួនមិនស្របតាមការសម្រេចរបស់មជ្ឈត្តការទេនោះ ភាគីនានាដែលចូលរួមក្នុងវេទិកាមជ្ឈត្តការអាចកែប្រែ ឬដកចេញនូវផលប្រយោជន៍

នានាដែលសមមូលស្មើរតែទាំងស្រុង អនុលោមតាមការសម្រេចទាំងនោះ ។ ទោះបីជាមានចែងក្នុងមាត្រា ២២ ក៏ដោយ ក៏ការកែប្រែ ឬដកចេញបែបនេះ អាចត្រូវបានអនុវត្តតែទៅលើភាគីកែប្រែប៉ុណ្ណោះ ។

## ជំពូក IV : បទប្បញ្ញត្តិផ្សេងៗ

### មាត្រា ២៥

### រដ្ឋាភិបាលកណ្ដាល តំបន់ និងមូលដ្ឋាន

ក្នុងការបំពេញកាតព្វកិច្ច និងការសន្យារបស់ខ្លួនក្នុងកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវធានាថា រដ្ឋាភិបាល និងអាជ្ញាធរ តំបន់ និងមូលដ្ឋាន នៅក្នុងដែនដីរបស់ខ្លួន ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល ប្រតិបត្តិតាមការណែនាំរបស់ខ្លួន (នៅក្នុងការអនុវត្តសិទ្ធិអំណាចដែលផ្ដល់ឱ្យដោយរដ្ឋាភិបាលកណ្ដាល រដ្ឋ តំបន់ ឬមូលដ្ឋាន ឬអាជ្ញាធរផ្សេងៗ) នៅក្នុងដែនដីរបស់ខ្លួន ។

### មាត្រា ២៦

### កន្លែងទំនាក់ទំនង

១. ភាគីនីមួយៗ ត្រូវកំណត់កន្លែងទំនាក់ទំនង ដើម្បីសម្រួលការទំនាក់ទំនងរវាងបណ្ដាភាគី អំពីបញ្ហាណាមួយ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ រួមទាំងការផ្លាស់ប្ដូរព័ត៌មានទាក់ទងនឹងការអនុវត្ត និងប្រតិបត្តិការ នៃកិច្ចព្រមព្រៀងនេះ ។

២. តាមការស្នើសុំរបស់ភាគីណាមួយ កន្លែងទំនាក់ទំនងនៃភាគីដែលត្រូវបានស្នើសុំ ត្រូវប្រាប់ពីការិយាល័យ ឬមន្ត្រីដែលទទួលខុសត្រូវលើបញ្ហានោះ និងជួយសំរួលដល់ការទំនាក់ទំនងជាមួយភាគី ដែលស្នើសុំ ។

### មាត្រា ២៧

### ការពិនិត្យឡើងវិញ

រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មចិន ឬតំណាងរបស់ពួកគេ ត្រូវជួបប្រជុំក្នុងរយៈពេលមួយឆ្នាំ គិតពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ហើយបន្ទាប់ពីនោះ ត្រូវជួបគ្នារៀងរាល់ពីរឆ្នាំម្ដង ឬបើមិនដូច្នោះទេ ត្រូវជួបគ្នាក្នុងចន្លោះពេលសមស្រប ដើម្បីពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងនេះ សំរាប់គោលបំណងនៃការពិចារណាលើការចាត់វិធានការបន្ថែមទៀត សំរាប់សេរីភាវូបនីយកម្មសេវាកម្ម និងដើម្បីបង្កើតវិន័យ និងចរចាលើកិច្ចព្រមព្រៀងនានាស្ដីពីបញ្ហាដែលមានចែងនៅក្នុងមាត្រា ១៥ ឬលើបញ្ហាពាក់ព័ន្ធដទៃទៀត តាមដែលអាចព្រមព្រៀងគ្នា ។

## មាត្រា ២៨
## បទប្បញ្ញត្តិផ្សេងៗ

១. ឧបសម្ព័ន្ធកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម គឺមាន ឧបសម្ព័ន្ធស្តីពីចលនារបស់រូបវន្តបុគ្គលដែលផ្គត់ផ្គង់សេវា ឧបសម្ព័ន្ធស្តីពីសេវាដឹកជញ្ជូនតាមផ្លូវអាកាស ឧបសម្ព័ន្ធស្តីពីសេវាហិរញ្ញវត្ថុ និង ឧបសម្ព័ន្ធស្តីពីទូរគមនាគមន៍ រួមទាំងការកែប្រែនានា ត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

២. កិច្ចព្រមព្រៀងនេះ ត្រូវរាប់បញ្ចូលនូវ (ក) ឧបសម្ព័ន្ធ និងមាតិការ នៅក្នុងនោះ នឹងត្រូវបង្កើតជាផ្នែកនៃកិច្ចព្រមព្រៀងនេះ និង (ខ) រាល់លិខិតុបករណ៍ច្បាប់អនាគតដែលបានព្រមព្រៀង ត្រូវ អនុលោមតាមកិច្ចព្រមព្រៀងនេះ ។

៣. លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងនេះ បើមិនដូច្នោះទេ កិច្ចព្រមព្រៀងនេះ ឬសកម្មភាពណាមួយដែលធ្វើឡើងក្រោមកិច្ចព្រមព្រៀងនេះ មិនត្រូវប៉ះពាល់ឬមោឃកម្ម ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីមួយ នៅក្រោមកិច្ចព្រមព្រៀងដែលមានស្រាប់ ដែលភាគីនោះជាភាគីឡើយ ។

## មាត្រា ២៩
## វិសោធនកម្ម

កិច្ចព្រមព្រៀងនេះ អាចត្រូវបានធ្វើវិសោធនកម្មដោយមានការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរពីបណ្តាភាគី ហើយវិសោធនកម្មទាំងនោះ នឹងត្រូវចូលជាធរមាននៅកាលបរិច្ឆេទ ឬបណ្តាកាលបរិច្ឆេទដែលបានព្រមព្រៀងគ្នាដោយបណ្តាភាគី ។

## មាត្រា ៣០
## ការដោះស្រាយវិវាទ

កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយវិវាទ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៣១
## ការបដិសេធផលប្រយោជន៍

ភាគីមួយអាចបដិសេធផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ :

ក. ចំពោះការផ្គត់ផ្គង់សេវាមួយ ប្រសិនបើរកឃើញថា សេវានោះត្រូវបានផ្គត់ផ្គង់ចេញមកពី ឬនៅក្នុងដែនដីនៃប្រទេសមិនមែនជាភាគី

ខ. ក្នុងករណីនៃការផ្គត់ផ្គង់សេវាដឹកជញ្ជូនផ្លូវសមុទ្រ ប្រសិនបើរកឃើញថា សេវាត្រូវបានផ្គត់ផ្គង់:

(i) ដោយនាវាដែលបានចុះបញ្ជីតាមច្បាប់របស់ប្រទេសមិនមែនភាគី និង

(ii) ដោយបុគ្គលនៃប្រទេសមិនមែនជាភាគី ដែលប្រតិបត្តិការ និង/ឬប្រើប្រាស់នាវានោះទាំងមូល ឬដោយផ្នែក ។

គ. ចំពោះអ្នកផ្គង់ផ្គង់សេវាដែលជានីតិបុគ្គល ប្រសិនបើរកឃើញថា នីតិបុគ្គលនោះមិនមែនជាអ្នកផ្គត់ផ្គង់សេវានៃភាគីម្ខាងទៀត។

## មាត្រា ៣២
## ការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាននៅថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០០៧ ។

២. បណ្តាភាគីត្រូវបញ្ចប់នូវនីតិវិធីក្នុងស្រុករបស់ខ្លួន ដើម្បីចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ឱ្យបានមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៧ ។

៣. នៅពេលភាគីណាមួយមិនអាចបញ្ចប់នីតិវិធីក្នុងស្រុករបស់ខ្លួនសំរាប់ការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះបានមុនថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៧ សិទ្ធិ និងកាតព្វកិច្ចនៃភាគីនោះក្រោមកិច្ចព្រមព្រៀងនេះ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃដែលបានបញ្ចប់នីតិវិធីក្នុងស្រុក ។

៤. បណ្តាភាគី បន្ទាប់ពីបានសម្រេចនូវនីតិវិធីក្នុងស្រុក សំរាប់ចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅបណ្តាភាគីដទៃទៀត ។

## មាត្រា ៣៣
## ការតម្កល់ទុក

សំរាប់រដ្ឋជាសមាជិកអាស៊ានទាំងអស់ កិច្ចព្រមព្រៀងនេះ ត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្តល់នូវសេចក្តីចម្លងតាមច្បាប់ដើមទៅប្រទេសសមាជិកអាស៊ាននីមួយៗ។

**ជាសក្ខីភាព** ហត្ថលេខីខាងក្រោមដែលទទួលបានសិទ្ធប្រទានពេញលេញពីរដ្ឋាភិបាល នៃប្រទេសនីមួយៗ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន ។

ធ្វើនៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៧ ច្បាប់ចម្លងជាភាសាអង់គ្លេស ។

**ប្រ៊ុយណេដារូស្សាឡាម**

MOHAMED BOLKAH
រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្ម

**សាធារណរដ្ឋប្រជាមានិតចិន**

LI ZHAO XING
រដ្ឋមន្ត្រីការទេស

**ព្រះរាជាណាចក្រកម្ពុជា**

**ចម ប្រសិទ្ធ**
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីពាណិជ្ជកម្ម

**សាធារណរដ្ឋឥណ្ឌូនេស៊ី**

MARI ELKA PANGESTU
រដ្ឋមន្ត្រីពាណិជ្ជកម្ម

**សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

NAM VIYAKETH
រដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្ម

**ម៉ាឡេស៊ី**

DATO'SERI RAFIDAH AZIZ
រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម

**សហភាពមីយ៉ាន់ម៉ា**

U SOE THA
រដ្ឋមន្ត្រីផែនការអន្តរជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច

**សាធារណរដ្ឋហ្វីលីពីន**

PETER B. FAVILA
រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

**សាធារណរដ្ឋសិង្ហបុរី**

LIM HNG KIANG
រដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម

**រាជាណាចក្រថៃឡង់ដ៍**

RIRK KRAI JIRAPAET
រដ្ឋមន្ត្រីពាណិជ្ជកម្ម

**សាធារណរដ្ឋសង្គមនិយមវៀតណាម**

TRUONG DINH TUYEN
រដ្ឋមន្ត្រីពាណិជ្ជកម្ម